00643808

F16/2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

ឯកឧត្តម គង់ ស្រ៊ឹម

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ស៊ិន រិទ្ធ

ចៅក្រម យ៉ា ណារិន

ចៅក្រម Motoo NOGUCHI

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម Chandra NIHAL JAYASINGHE

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 02 / 2011
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០១១

**កម្មវត្ថុ៖ ចម្លើយតបរបស់អង្គភាពគាំពារការការពារក្តីចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គភាពគាំពារការការពារក្តី សុំឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន តាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អវតក**

លោកចៅក្រមជាទីគោរព!

1. អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”) អង្គភាពគាំពារការការពារក្តី (“DSS”) សូមដាក់ចម្លើយតបរបស់ខ្លួនចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់របស់អង្គភាព DSS សុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តអំណាចរបស់ខ្លួន តាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងរបស់ អវតក (“ចម្លើយតបរបស់សហព្រះរាជអាជ្ញា”)[1] ។

2. អង្គភាព DSS នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ បានដាក់លិខិតមួយច្បាប់នៅអង្គជំនុំជម្រះតុលាការកំពូល ស្នើសុំឱ្យអង្គជំនុំជម្រះនេះអនុវត្តអំណាចរបស់ខ្លួន តាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់អង្គភាព DSS សុំអង្គជំនុំជម្រះតុលាការកំពូលអញ្ជើញឱ្យមានាការសារណារបស់អ្នកដែលមិនមែនក្នុងរឿងក្តី ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ F16/1 ។

00643809

F16/2

ដោយអញ្ជើញភាគីទីបីឯករាជ្យឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដី ដើម្បីធានាឱ្យមានការបង្ហាញយ៉ាងពេញលេញនូវអំណះអំណាងផ្នែកច្បាប់នានាទាក់ទងនឹងបញ្ហាដែលបានលើកឡើងនៅក្នុងបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ហើយដែលមកដល់ពេលនេះមិនត្រូវបានលើកឡើងដោយសហមេធាវីនៅក្នុងនីតិវិធី ជាពិសេស បញ្ហាទាក់ទងនឹងការផ្ដន្ទាទោស ("សំណើរបស់អង្គភាព DSS")[2] ។

3. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១ អង្គភាព DSS បានទទួលការជូនដំណឹងពីការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាទទួលស្គាល់នៅក្នុងចម្លើយតបរបស់ពួកគេថា "ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលជឿជាក់ថា ការដាក់សារណាបន្ថែមលើបញ្ហាពិសេស នឹងជួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការសម្រេចលើបណ្ដឹងសារទុក្ខរបស់ភាគី" សហព្រះរាជអាជ្ញា "នឹងគាំទ្រការអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដី ពីសំណាក់ភាគីទីបីដ៏សក្ដិសម និងឯករាជ្យ"[3]។ ទោះជាយ៉ាងដូច្នេះក៏ដោយ សហព្រះរាជអាជ្ញាចាត់ទុកថាជាការមិនត្រឹមត្រូវទេ "សម្រាប់អង្គជំនុំជម្រះតុលាការកំពូលក្នុងការស្នើសុំសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដី យកមកផ្ដល់សំអាងជួសមុខឱ្យជនជាប់ចោទនោះ"[4] និងបានចោទប្រកាន់ថា អង្គភាព DSS "ទំនងជាបានលើកទឹកចិត្តឱ្យមានការចាត់តាំងតាមព្រឹត្តិន័យនូវមេធាវីការពារក្ដីអន្តរជាតិសម្រាប់ជនជាប់ចោទ [...] ខណៈដែលជនជាប់បានជ្រើសរើសដោយស្ម័គ្រចិត្តមិនព្រមទទួលយកការណែនាំពីមេធាវីអន្តរជាតិនោះ"[5] ។

**ចម្លើយតបទៅនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញា**

(i) <u>"ចំពោះការអះអាងរបស់សហព្រះរាជអាជ្ញាថា អង្គភាព DSS "ទំនងជាបានលើកទឹកចិត្តឱ្យមានការចាត់តាំងតាមព្រឹត្តិន័យ នូវមេធាវីអន្តរជាតិសម្រាប់ជនជាប់ចោទ"</u>

---

[2] "សំណើអង្គភាព DSS សុំអង្គជំនុំជម្រះតុលាការកំពូលអនុវត្តឈរអំណាចរបស់ខ្លួន ក្រោមវិធាន ៣៣" ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១, ឯកសារ F16 ។

[3] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី២ ។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី៣ ។

[5] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី៤ ។

F16/2

4. មេធាវីការពារក្ដីស្នើឱ្យពិចារណាថា សហព្រះរាជអាជ្ញាយល់ខុសចំពោះសំណើរបស់អង្គភាព DSS ។ ពុំមានមូលដ្ឋានណានៅក្នុងខ្លឹមសារនៃសំណើរបស់អង្គភាព DSS ដើម្បីគាំទ្រដល់ការអះអាងរបស់សហព្រះរាជអាជ្ញាឡើយ ។

5. ការស្នើសុំអង្គជំនុំជម្រះតុលាការកំពូលអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដីពីសំណាក់ភាគីទីបីឯករាជ្យ "ដើម្បីធានាឱ្យមានការបង្ហាញយ៉ាងពេញលេញនូវអំណះអំណាងផ្នែកច្បាប់ទាក់ទងនឹងបញ្ហានានា ដែលបានលើកឡើងនៅក្នុងបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា"[6] អង្គភាព DSS កំពុងតែគោរពតាមយ៉ាងច្បាស់នូវអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីសម្រេចលើចរិតលក្ខណៈ និងទំហំនៃការអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដីដែលបានស្នើសុំ ។

6. សំណើរបស់អង្គភាព DSS បញ្ជាក់យ៉ាងច្បាស់ថា គោលបំណងរបស់សំណើនេះគឺដើម្បីធានាថាបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ហើយដែលមកដល់ពេលនេះមិនត្រូវបានលើក រួមទាំងអំណះអំណាងរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការផ្ដន្ទាទោស ការផ្ដន្ទាទោសត្រួតគ្នា និងការធ្វើឱ្យទៅទាសករ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[7] ត្រូវបានលើកឡើងជាលាយលក្ខណ៍អក្សរ ។ វាជាផលប្រយោជន៍របស់ភាគីទាំងអស់នៃដំណើរការនីតិវិធីនេះដែលបញ្ហានានាត្រូវបានបង្ហាញយ៉ាងពេញលេញ ដើម្បីធានាថាបណ្ដឹងសារទុក្ខត្រូវបានសម្រេចយ៉ាងត្រឹមត្រូវ ។

7. សហព្រះរាជអាជ្ញាយោងកថាខណ្ឌទី១១ នៃសំណើរបស់អង្គភាព DSS ថាជាភស្តុតាងបញ្ជាក់ពីការប៉ុនប៉ងរបស់អង្គភាព DSS ដើម្បីលើកទឹកចិត្តឱ្យមានការចាត់តាំងតាមព្រឹត្តិន័យនូវមេធាវីអន្តរជាតិ ។ ផ្ទុយទៅវិញ កថាខណ្ឌនេះមានបំណងជម្រាបអង្គជំនុំជម្រះតុលាការកំពូលពីទម្លាប់អនុវត្តនៅកម្រិតអន្តរជាតិលើជម្រើសជាច្រើនដែលអង្គជំនុំជម្រះអាចរកបាន ដើម្បីអនុវត្តអំណាចរបស់ខ្លួនក្នុងការអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្ដី[8] ។

---

[6] សំណើរបស់អង្គភាព DSS នៅកថាខណ្ឌទី១៦ ។

[7] បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់ជំនុំជម្រះសាលាដំបូងនៅក្នុងករណី កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ នៅកថាខណ្ឌទី២២-២០៩។

[8] មាត្រា ១២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដី នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ "នៅពេលដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាមួយដែលពាក់ព័ន្ធក្នុងច្បាប់

00643811

F16/2

8. អង្គភាព DSS កត់សម្គាល់ថាសហព្រះរាជអាជ្ញាកំពុងតែមានឆន្ទៈគាំទ្រការអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ដរាបណាការអញ្ជើញអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តីឱ្យដាក់សារណាមិនលំអៀង ទៅលើបញ្ហាសំខាន់នោះ[9]។ ដោយថ្លែងថា "សហព្រះរាជអាជ្ញាមិនជឿថា វាជាការត្រឹមត្រូវសម្រាប់អង្គជំនុំជម្រះតុលាការកំពូលក្នុងការស្នើសុំសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី យកមកផ្តល់សំអាងជួសមុខឱ្យជនជាប់ចោទ"[10] សហព្រះរាជអាជ្ញាទំនងជាលើកឡើងថាអង្គជំនុំជម្រះតុលាការកំពូលមិនមានឆន្ទានុសិទ្ធិ ដើម្បីអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ដើម្បីជួយអង្គជំនុំជម្រះតុលាការកំពូលវាយតម្លៃលើអំណះអំណាងរបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងនៅក្នុងបណ្តឹងសារទុក្ខរបស់ពួកគេ ដែលមិនត្រូវបានលើកឡើងដោយសហមេធាវីរបស់ជនជាប់ចោទ ។

9. សំណើរបស់សហព្រះរាជអាជ្ញា នឹងដាក់កម្រិតឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូល និងមិនសមស្របទៅនឹងខ្លឹមសារនៃវិធាន ៣៣ នៃវិធានផ្ទៃក្នុង ដែលផ្តល់ឆន្ទានុសិទ្ធិដល់អង្គជំនុំជម្រះតុលាការកំពូលអញ្ជើញ ឬផ្តល់ឱកាសឱ្យអង្គការ ឬបុគ្គលណាមួយឱ្យដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ពាក់ព័ន្ធនឹងបញ្ហា*ណាមួយ* ។ ផ្អែកតាមការបកស្រាយយ៉ាងច្បាស់នៃវិធាន៣៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនៅ អវតក មានឆន្ទានុសិទ្ធិក្នុងការអញ្ជើញឱ្យមានការដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* បើខ្លួនយល់ថាចាំបាច់ដើម្បីធ្វើការ "វិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ[11] " ។

10. អង្គភាព DSS សូមអះអាងជាថ្មីម្តងទៀតថាគោលជំហររបស់ខ្លួនត្រូវបានគាំទ្រដោយយុត្តិសាស្ត្រ និងការអនុវត្តល្អបំផុតដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ ក្នុងករណី Krajisnik[12] អង្គជំនុំ

---

កម្ពុជា ឬមានបញ្ហាទាក់ទងនឹងភាពសមស្របគ្នា រវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ។

[9] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី ៥(ខ) ។

[10] ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌទី ៣ ។

[11] ឆន្ទានុសិទ្ធិរបស់តុលាការលើបញ្ហានេះ ក៏ស៊ីសង្វាក់គ្នាទៅនឹងវប្បធម៌នៃនីតិវិធីដែលដឹកនាំដោយចៅក្រមដែលបានបង្កើតឡើងនៅក្នុងទំនៀមទម្លាប់ច្បាប់ស៊ីវិលផងដែរ។

[12] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Momcilo Krajisnik*, សំណុំរឿងលេខ IT-00-39-A, សេចក្តីសម្រេចលើសំណើសុំការពារក្តីដោយខ្លួនឯងរបស់ *Momcilo Krajisnik* , សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីទាក់ទងនឹងការចាត់តាំងអ្នកដែលមិនមែនជាភាគីនៃរឿងក្តី និសេចក្តីសម្រេចលើពាក្យសុំរបស់ព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៧, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ("សេចក្តីសម្រេលើសំណើសុំរបស់ *Krajisnik* ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧")។

00643812

F16/2

ជម្រះតុលាការកំពូលនៅ ICTY[13] បានបង្គាប់ឱ្យមានការចាត់តាំងអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី "ក្នុងគោលបំណងលើកទឡ្ហីករណ៍នៃបណ្តឹងសារទុក្ខ ដើម្បីស្វែងរកនូវការបដិសេធចោទនូវការផ្តន្ទាទោស ឬឱ្យមានការសម្រាលទោស និងដើម្បីផ្តល់ទឡ្ហីករណ៍ប្រឆាំងនឹងមូលហេតុនៃបណ្តឹងសារទុក្ខរបស់ព្រះរាជអាជ្ញា[14]" ដោយសង្កត់ធ្ងន់ថា " អង្គជំនុំជម្រះតុលាការកំពូលអាចស្នើអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ឱ្យលើកសំអាងគាំទ្រផលប្រយោជន៍របស់ភាគីណាមួយនៅពេលដែលមធ្យោបាយបែបនេះបម្រើដល់ផលប្រយោជន៍ខាងយុត្តិធម៌[15]"។

11. ការប៉ុនប៉ងរបស់សហព្រះរាជអាជ្ញាក្នុងការធ្វើឱ្យករណីនេះ ខុសគ្នានឹងករណីនៅតុលាការ ICTY ដោយអះអាងថាយុត្តិសាស្ត្រនៅ ICTY ដែលបានលើកឡើងក្នុងសំណើរបស់អង្គភាព DSS ពាក់ព័ន្ធនឹងជនជាប់ចោទ[16] ដែល"ការពារក្តីដោយខ្លួនឯង" គឺជាការធ្វើឱ្យខុសពីគ្នាក្លែងក្លាយប៉ុណ្ណោះ ។ គោលបំណងដ៏សំខាន់នៃអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល អញ្ជើញឱ្យមានការដាក់សារណារបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គឺដើម្បីធានាឱ្យមាន"ការវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ" និងដើម្បីបម្រើផលប្រយោជន៍យុត្តិធម៌ ដោយធានាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ អង្គជំនុំជម្រះតុលាការកំពូលនៅ ICTY បានបញ្ជាក់យ៉ាងច្បាស់ពីបញ្ហានេះក្នុងករណី Krajisnik ដោយអះអាងថា ជនជាប់ចោទគ្មានសិទ្ធិទទួលបានការលើកមកសំអាងពីអ្នកដែលមិនមែនជាភាគីនៃរឿងក្តីឡើយ ព្រោះគាត់ការពារក្តីដោយខ្លួនឯង ប៉ុន្តែបញ្ហាគឺនៅត្រង់ថា តើអង្គជំនុំតុលាការកំពូលចាត់ទុកថាការចាត់តាំងអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ជាការចាំបាច់ដែរ ឬទេ បើពិចារណាពីតួនាទីរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការធានាថាបណ្តឹងសារទុក្ខពិតត្រូវតែយុត្តិធម៌[17]។

---

[13] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY)។

[14] សេចក្តីសម្រេចលើសំណើរបស់ *Krajisnik* ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧, កថាខណ្ឌទី១៩។

[15] សេចក្តីសម្រេចលើសំណើរបស់ *Krajisnik* ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ នៅកថាខណ្ឌទី១៧ ។ សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង Theoneste Bagosora សំណុំរឿងលេខ ICTR-96-7-T, សេចក្តីសម្រេចលើពាក្យសុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្របែលហ្ស៊ិក, ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៩៨៖ "ដោយចាត់ទុកជាបញ្ហាបឋមមួយ យើង(អង្គជំនុំជម្រះ) បានកត់សម្គាល់ថានិយមន័យទូទៅនៃសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី <u>មិនតម្រូវឱ្យមានឥតលម្អៀងពីភាគីដាក់សារណាឡើយ</u>"។

[16] ចម្លើយតបរបស់សហព្រះរាជអាជ្ញា, ជើងទំព័រទី៤។

[17] សេចក្តីសម្រេចលើសំណើរបស់ *Krajisnik* ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ត្រង់កថាខណ្ឌទី១៨, សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង Morris Kallon, សំណុំរឿងលេខ SCSL-2003-07, សេចក្តីសម្រេចលើពាក្យសុំរបស់ Redress Trust, គណៈកម្មការមេធាវីទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ សុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃ

F16/2

អនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងនៅ អវតក អំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល មិនអាចត្រូវបានគេបកស្រាយតាមលក្ខណៈតូចចង្អៀតបែបនេះឡើយ ដោយផ្អែកលើលក្ខណៈនៃការការពារក្តីរបស់ជនជាប់ចោទ[18]។

12. ជាងនេះទៅទៀត សហព្រះរាជអាជ្ញាបានលើកឡើងថាការអញ្ជើញកាលពីលើកមុនរបស់អង្គបុរេជំនុំជម្រះ (“អបជ”) នៅ អវតក ឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី មិនបង្កើតបានជា “សំណើសុំឱ្យអ្នកមិនមែនជាភាគីនៃរឿងក្តីលើកសំអាងគាំទ្រភាគីជាក់លាក់ណាមួយនោះទេ[19]” ។ នៅក្នុងអញ្ជើញឱ្យមានការដាក់សារណាពីសំណាក់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី អង្គបុរេជំនុំជម្រះបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយជ្រើសពាក្យពេចន៍ណាដែលសាកសមបំផុត ដើម្បីឱ្យមានការវិនិច្ឆ័យទោសត្រឹមត្រូវ ។ ការដែលលើកឡើងថាអង្គជំនុំជម្រះតុលាការកំពូលចងភ្ជាប់កាតព្វកិច្ចដោយពាក្យពេចន៍ដែលប្រើដោយអង្គបុរេជំនុំជម្រះ នឹងដាក់កម្រិតឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូលលើបញ្ហាទាំងនេះ ដោយមិនសមហេតុផល។

13. នៅទីបញ្ចប់ សហព្រះរាជអាជ្ញាលើកឡើងថា “ដើម្បីការពារប្រយោជន៍ និងបំណងប្រាថ្នារបស់ជនជាប់ចោទ មេធាវីចាំបាច់ត្រូវតែទទួលបានការណែនាំពីជនជាប់ចោទខ្លួនឯងផ្ទាល់[20]”។ ដោយបានលើកឡើងនូវអំណះអំណាងនេះ សហព្រះរាជអាជ្ញាបានបកស្រាយខុសជាថ្មីម្តងទៀតនូវគោលបំណងដ៏សំខាន់នៃអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី[21]។

---

រឿងក្តី និងសារណាផ្ទាល់មាត់, ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៣ (“សេចក្តីសម្រេចលើពាក្យសុំរបស់ Kallon ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៣”) ត្រង់កថាខណ្ឌទី៥។

[18] សេចក្តីសម្រេចលើពាក្យសុំរបស់ Kallon ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៣៖ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឱ្យអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដែលទទ្បីករណ៍របស់គេនឹងមានប្រយោជន៍យ៉ាងច្បាស់ដល់ប្រយោជន៍របស់ជនជាប់ចោទឱ្យធ្វើអន្តរាគមន៍លើរឿងក្តីនេះទោះបីជាជនជាប់ចោទបានទទួលជំនួយពីមេធាវីការពារក្តីក៏ដោយ។

[19] ចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រង់កថាខណ្ឌទី៣។

[20] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ត្រង់កថាខណ្ឌទី៤៖ សហព្រះរាជអាជ្ញាមិនបានលើកឡើងនូវអំណាចណាមួយដើម្បីគាំទ្រការសន្និដ្ឋានេះទេ។

[21] សូមមើលផងដែរនូវសេចក្តីសម្រេចលើពាក្យសុំរបស់ Kallon ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៣ កថាខណ្ឌទី៥៖ “[..វិធានស្តីពីការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី] មិនបានបែងចែករវាងផលប្រយោជន៍ផ្សេងគ្នានៃភាគីដែលចង់ធ្វើអន្តរាគមន៍ឡើយ។ វិធាននេះផ្តោតតែលើជំនួយជាសក្តានុពលដែលពួកគេអាចផ្តល់ឱ្យតុលាការ”។ សាមញ្ញបំផុត “<u>ការវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ គឺសំដៅដល់តុលាការដែលអាចធ្វើសេចក្តីសម្រេចមួយស្របទៅតាមយុត្តិធម៌ចុងក្រោយ</u>” ។

14. ក្នុងករណីដែលអង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា រាល់អំណះអំណាងទាំងអស់លើបញ្ហាពិសេសដែលចាំបាច់សម្រាប់ការវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ មិនត្រូវបានគេលើកឡើងឱ្យបានគ្រប់គ្រាន់ នោះអង្គជំនុំជម្រះតុលាការកំពូលអាចអញ្ជើញភាគីខាងក្រៅដែលឯករាជ្យឱ្យដាក់បន្ថែមលើបញ្ហាចន្លោះប្រហោង ។ សារណាដែលដាក់តាមការអញ្ជើញបែបនេះមិនមែនជាការដាក់សារណារបស់ភាគីជួសមុខឱ្យជនជាប់ចោទឡើយ[22] ហើយអង្គជំនុំជម្រះមិនមានកាតព្វកិច្ចដោះស្រាយរាល់អំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាឡើយ ។ សារណាបែបនេះគឺដើម្បីជំនួយដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងការវាយតម្លៃ "ថាតើផលប្រយោជន៍ខាងយុត្តិធម៌តម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូល ពិចារណាលើបញ្ហានានាដែលមិនបានលើកឡើងនៅក្នុងបណ្តឹងសារទុក្ខរបស់ជនជាប់ចោទ ឬក្នុងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាដែរ ឬយ៉ាងណា[23]"។ គួរកត់សម្គាល់ផងដែរថាសាលដីកាលើបណ្តឹងសារទុក្ខក្នុងដំណើរការនីតិវិធីនេះ នឹងមានតម្លៃស្មើនឹងសាលដីកាស្ថាពរដែលបិទផ្លូវប្តឹងតវ៉ា ។

**សំណើ**

15. អាស្រ័យលើហេតុផលដូចដែលបានគូសបញ្ជាក់ពីខាងលើ អង្គភាព DSS៖

ក. ស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូលច្រានចោលអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថាការអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី សមស្របតាមវិធាន៣៣ នៃវិធានផ្ទៃក្នុង ត្រូវដាក់កម្រិតត្រឹមតែសំណើណាដែលផ្តល់សារណាឯករាជ្យ និង ឥតលម្អៀង លើបញ្ហាពិសេសណាមួយ ឬក៏បញ្ហាដែលជាក្តីកង្វល់ និង

[22] សូមមើល *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Slobodan Milosovic,* សំណុំរឿងលេខ IT-02-54, ដីកាបង្គាប់ឱ្យចាត់តាំងអ្នកដែលមិនមែនជាភាគីនៃរឿងក្តី, ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១៖ "ដូច្នេះអង្គជំនុំជម្រះចាត់ទុកវាជាការចាំបាច់ ហើយដើម្បីជាប្រយោជន៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ អង្គជំនុំជម្រះសម្រេចឱ្យមានការចាត់តាំងអ្នកដែលមិនមែនជាភាគីនៃរឿងក្តីដូចដែលបានអនុញ្ញាតដោយវិធាននីតិវិធី និងភស្តុតាង ពោលគឺ<u>មិនមែនដើម្បីការពារជនជាប់ចោទទេ ប៉ុន្តែដើម្បីជួយតុលាការក្នុងការវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ</u> (អង្គជំនុំជម្រះនៅតែបន្តអញ្ជើញឱ្យមានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដើម្បីជួយតុលាការដោយធ្វើសេចក្តីសន្និដ្ឋានតាមវិធីដាក់សំណើ ការសួរបដិសាក្សី ដោយទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះមកលើភស្តុតាងដោះបន្ទុក ឬក៏ភស្តុតាងដែលនាំឱ្យមានស្ថានសំរាលទោស និងដោយអនុវត្តតាមវិធីផ្សេងទៀតដែលមេធាវីដែលត្រូវបានចាត់តាំងចាត់ទុកថាត្រឹមត្រូវដើម្បីធានាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌")។

[23] សេចក្តីសម្រេចលើសំណើសុំរបស់ *Krajisnik* ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ត្រង់កថាខណ្ឌទី២០។

00643815

F16/2

ខ. សូមបញ្ជាក់ជាថ្មីម្តងទៀតពីសំណើលើកទី១ របស់អង្គភាព DSS សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន សមស្របតាមវិធាន៣៣ នៃវិធានផ្ទៃក្នុង និងអញ្ជើញឱ្យ មានការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីដោយភាគីទី៣ឯករាជ្យ ដើម្បីធានាថាអំណះអំណាងផ្នែកច្បាប់នានាទាក់ទងនឹងបញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងសារទុក្ខរបស់សហព្រះរាជអាជ្ញា ហើយមកដល់ពេលនេះ មិនត្រូវបានលើកឡើងដោយសហមេធាវីនៅក្នុងនីតិវិធី ជាពិសេស បញ្ហានៃការផ្តន្ទាទោស ត្រូវបានបង្ហាញយ៉ាងពេញលេញ ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

Rupert Abbott
**មន្ត្រីទទួលបន្ទុក**
**អង្គភាពគាំពារការការពារក្តី**